តុលាការកំពូល

សភាផ្នែករដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណី

លេខ : ៤៥៤

ចុះថ្ងៃទី២៥ខែវិច្ឆិកាឆ្នាំ២០០០

សាលដីកា

លេខ : ៨០

ចុះថ្ងៃទី២៩ខែឧសភាឆ្នាំ២០០១

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

បានបើកសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៩ ខែឧសភា ឆ្នាំ ២០០១ ដោយមានសមាសភាពដូចតទៅ :

១_ ឯកឧត្តម ឌិត មុន្ទី ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ

២_ លោក ប៉ែន ស៊ិន ជាចៅក្រម

៣_ លោក យឹម ស៊ីផល ជាចៅក្រម

៤_ លោក ព្រាក់ គឹមសាន ជាចៅក្រមរបាយការណ៍

៥_ លោក យស់ សុខឿន ជាចៅក្រម

ក្រឡាបញ្ជី

អ្នកស្រី អ៊ី រមនា

តំណាងមហាអយ្យការ

ឯកឧត្តម ជួន ស៊ុនឡេង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ ១៥៦ "ង" ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៧០៣ ចុះថ្ងៃទី ២៦.១០.១៩៩៩ របស់សាលាឧទ្ធរណ៍រវាង :

ម្ចាស់បណ្តឹងសាទុក្ខអ្នកស្រី លាស់ រឿន អាយុ ៦០ឆ្នាំ ជាតិ ខ្មែរ មុខរបរ នៅផ្ទះ ទីលំនៅ ផ្ទះលេខ ១៧ "ភ" ក្រុម២១ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ មានមេធាវីលោក មៀច សអ៊ាន់

និងចុងបណ្តឹងសាទុក្ខលោក អៀង ម៉េងហាង អាយុ ៤៨ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករ ទីលំនៅ ផ្ទះ១៨ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

កម្មវត្ថុបណ្តឹង : ប្តឹងសុំអោយលប់រណ្តៅបើកផ្លូវចេញចូល

តាមបណ្តឹងសាទុក្ខលេខ ៣៩៨ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០០ របស់អ្នកស្រី លាស់ វឿន ប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ ១៥៦ "ង" ចុះថ្ងៃទី-០៣.១០.២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ៥៥៤ ចុះថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០០០ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ លាស់ វឿន ចុះថ្ងៃទី ២៥ ខែ -ឧសភា ឆ្នាំ ១៩៩៨ ថា ខ្លួនសុំប្តឹងអោយឈ្មោះ អៀង ម៉េងហ៊ាង លុបរណ្តៅ និង បើកច្រកផ្លូវចេញចូលទៅផ្ទះខ្លួន និង សុំចម្លងសោរចាក់បើកទ្វារច្រកចេញចូលដោយអាងហេតុថា ច្រកផ្លូវចេញចូលទៅផ្ទះរបស់ខ្លួននេះ ក្រុមគ្រួសាររបស់ខ្លួន និង គ្រួសាររបស់អៀងម៉េង-ហ៊ាង ធ្លាប់ប្រើប្រាស់ចេញ ចូលរួមជាមួយគ្នាតាំងពីឆ្នាំ ១៩៧៩មកម្លេះ ។ លុះមកដល់ថ្ងៃទី០៥-៥.៩៨ វេលាម៉ោង ១០ម ២៥នាទី ឈ្មោះ អៀង ម៉េងហ៊ាង បានមកសុំខ្លួនកាប់ដើមទឹកដោះគោនៅក្នុងព្រំដីរបស់ខ្លួនដោយបានសន្យារក្សាទុកផ្លូវចេញ ចូល ជាធម្មតា ។ នៅថ្ងៃទី២៥-៥-៩៨ ឈ្មោះ អៀង ម៉េងហ៊ាង បានធ្វើរបងថ្មកាត់តាមព្រំប្រទល់ដីរហូតមកជិតកៀនផ្លូវមាត់ជណ្តើរខ្លួនទៀត ។ ហើយនៅថ្ងៃទី ០២.៥.៩៨ ចុងចម្លើយ និង ក្រុមគ្រួសារបាននាំគ្នាមកជីករណ្តៅជម្រៅ ០១ម៉ែត្រ ទទឹង១ ,២០ម៉ែត្រ និង បណ្តោយប្រវែង ០២ម៉ែត្រ បង្កហេតុបិទផ្លូវច្រក ចេញ ចូល ទៅផ្ទះរបស់ខ្លួន ។

តាមពាក្យបណ្តឹងតបរបស់ចុងចម្លើយឈ្មោះ អៀង ម៉េងហ៊ាង ចុះថ្ងៃទី ១៥-៦-៩៨ ថា ខ្លួនប្តឹងសុំធ្វើរបងបិទករឡេងទំនាប់ប្រវែង ២ ,៣០ម៉ែត្រ ដោយហេតុថា ដើម្បីរក្សាសុវត្ថិភាពក្នុងគ្រួសារ និង សុវត្ថិភាពលំនៅដ្ឋាន ព្រោះនៅក្នុងភូមិ ឃុំ មិនសូវមានសុវត្ថិភាពទើ្បយ ហើយសព្វថ្ងៃក៏មានការកើតទំនាស់រវាងអ្នកភូមិផងរបងជាមួយពីបញ្ហាព្រំដីនេះទៀតផង ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៣៨ "យ" ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងភ្នំពេញ បានសំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- បដិសេធពាក្យបណ្តឹងចុះថ្ងៃទី ២៥.៥.៩៨ របស់ដើមចោទឈ្មោះ -លាស់ វឿន ចោលជាអសារបង់ ។

២- ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១៥.៦.៩៨ របស់ចុងចម្លើយឈ្មោះអៀងម៉េង-ហ៊ាង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

៣- អោយឈ្មោះ អៀង ម៉េងហ៊ាង ធ្វើរបងបិទព្រំដីមានប្រវែងពីរម៉ែត្រ

--- ---

សាមសិបសង់ទីម៉ែត្រ ២,៣០ម ៘ ដីឡូតិ៍របស់ចុងចម្លើយ នៅភូមិទួលរការ សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ក្រុងភ្នំពេញ ចាប់ពីសាលក្រមចូលជាស្ថាពរ ។ ផ្តល់សិទ្ធិអោយឈ្មោះ លាស់ វឿន ដោះស្រាយបើកផ្លូវដើរ ចេញ ចូលផ្ទះរបស់ខ្លួនតាមគំនូសប្លង់ភូមិបាលខណ្ឌមានជ័យលេខ ០៨៦-៩៥ ចុះថ្ងៃទី ១៦-៣-៩៥ និង មាត្រា ១២២, ១២៣ នៃច្បាប់ភូមិបាល។

៤- រឹបអូសប្រាក់ប្រដាប់ក្តីរបស់ឈ្មោះ លាស់ វឿន គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល អ្នកប្រគល់ដីកាកោះ ៣.០០០-រៀល រង្វាន់សាក្សី ២.០០០រៀល សរុប ៧.០០០រៀល ដែលដើមចោទបានបង់រួចហើយ។

៥- បង្គាប់អោយឈ្មោះ លាស់ វឿន បង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ១.៨០០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល អ្នកប្រគល់ដីកាកោះ ៣.០០០រៀល រង្វាន់សាក្សី ២.០០០រៀល សរុប ៧.០០០ រៀល ដែលចុងចម្លើយបានបង់ទុកជាស្រេច ។

កាលបើហួសឧទ្ធរណ៍បង្គាប់អោយដើមចោទសងប្រាក់ ៧.០០០រៀល ទៅអោយចុងចម្លើយវិញ ។

៦- សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខគូភាគី សំរេចបើកផ្លូវប្តឹងឧទ្ធរណ៍កំណត់ ០២ខែ គិតចាប់ពីថ្ងៃនេះតទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៤"យ" ចុះថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៥ អ្នកស្រី លាស់ វឿន បានប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ៣៨"យ" ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់តុលាការក្រុងភ្នំពេញលើខ្លឹមសារនៃសេចក្តីសំរេចរបស់សាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៦២"ង" ចុះថ្ងៃទី ១១ ខែ មេសា - ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍បានសំរេចចំពោះមុខដើមបណ្តឹងឧទ្ធរណ៍ កំបាំងមុខចុងបណ្តឹងឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ១៦.៧.១៩៩៥ របស់ឈ្មោះ លាស់ វឿន ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៣៨"យ" ចុះថ្ងៃទី ១៣.៧.៩៥ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៣- អនុញ្ញាតិអោយបើកផ្លូវ ១ម៉ែត្រ ទទឹងនៅផ្នែកកន្ទុយដីរបស់អៀង ម៉េង-ហាង សំណូមពរលើសពីនេះបដិសេធចោល ។

៤- សំរេចកាត់យកប្រាក់ប្រដាប់ក្តីនៅជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹង ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥.០០០រៀល និង លើអាជ្ញាធរតុលាការ ៥.០០០រៀល។

៥- កាលបើសាលដីកា ចូលជាស្ថាពរបង្គាប់អោយឈ្មោះ អៀង ម៉េងហាង

--- ---

សងប្រាក់ ១៣.០០០រៀល ទៅឈ្មោះ លាស់ រឿន វិញ ។

៦- សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងឧទ្ធរណ៍ កំបាំងមុខចុងបណ្តឹងឧទ្ធរណ៍ ។ បើកផ្លូវប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងទាស់លេខ ៤៦ ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០០ របស់លោក អៀង ម៉េងហាង បានប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៦២ "ង" ចុះថ្ងៃទី១១ ខែ មេសា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍លើខ្លឹមសារនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ១៥៦ "ង" ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍បានសំរេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី ០២.៥.២០០០ របស់ឈ្មោះ អៀង ម៉េងហាង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២- បដិសេធសាលដីការដ្ឋប្បវេណីកំបាំងមុខលេខ ៦២ "ង" ចុះថ្ងៃទី ១១.៤.២០០០ របស់សាលាឧទ្ធរណ៍ចោលជាអសារបង់ ។

៣- អនុញ្ញាតិអោយឈ្មោះ អៀង ម៉េងហាង ធ្វើរបងបិទព្រំដីមានទទឹង ២,៣០ម ដីឡូតិ៍របស់ចុងចម្លើយនៅភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ ក្រុងភ្នំពេញ ទៅពេលដែលសាលដីកានេះចូលជាស្ថាពរ ។

៤- ផ្តល់សិទ្ធិអោយឈ្មោះ លាស់ រឿន ដោះស្រាយបើកផ្លូវដើរចេញចូលរបស់ខ្លួនតាមប្លង់ និង យោបល់របស់ស្ថាប័នជំនាញចុះថ្ងៃទី ១៦.៣.១៩៩៩ ។

សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៣៩៨ ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០០០ របស់អ្នកស្រី លាស់ រឿន បានប្តឹងមិនសុខចិត្តនឹងសេចក្តីសំរេចនៃសាលដីកាលេខ ១៥៦ "ង" ចុះថ្ងៃទី០៣-១០-២០០០ របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី ២៧.១២.២០០០របស់អ្នកស្រី លាស់ រឿន ។

បានឃើញសារណាតបចុះថ្ងៃទី ២៩.០១.២០០១ របស់លោក អៀង ម៉េងហាង ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីការដ្ឋប្បវេណីលេខ ១៥៦ "ង" ចុះថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ។

បានស្តាប់ចម្លើយរបស់អ្នកស្រី លាស់ រឿន ជាដើមចោទ និង ជាម្ចាស់បណ្តឹងសាទុក្ខ បានឆ្លើយនៅពេលសវនាការថា : ខ្លួនបានមករស់នៅលើដីនេះតាំងពីឆ្នាំ ១៩៧៩ មកម្លេះហើយ

--- ---

បានដើរចេញចូលមកផ្លូវសាធារណៈកាត់តាមដីរបស់ឈ្មោះ អៀង ម៉េងហ៊ាង នៅឆ្នាំ១៩៥៨ ឈ្មោះ អៀង ម៉េងហ៊ាង បានជីករណ្តៅផ្តាច់ផ្លូវ និង ធ្វើផ្ទះបិទផ្លូវពុំអាចអោយក្រុមគ្រួសារខ្លួនចេញចូលកើត ហើយសព្វថ្ងៃនេះខ្លួន និង ក្រុមគ្រួសារបានចេញពីផ្ទះនិងដីទៅនៅក្នុងខុមអ្នកតាក្រោមដើមពោធិ៍រយៈពេល៣ឆ្នាំហើយ ហេតុនេះខ្លួនសូមអោយបានច្រកចេញចូលទៅផ្ទះនិងដីរបស់ខ្លួន ។

បានស្តាប់ចម្លើយរបស់លោក អៀង ម៉េងហ៊ាង ជាចុងចម្លើយនិងជាចុងបណ្តឹងសាទុក្ខ បានឆ្លើយនៅពេលសវនាការថា : ខ្លួនសូមជំរាបតុលាការថាដោយ លាស់ វឿន នេះបានចាកចេញពីលំនៅដ្ឋានទៅរស់នៅព្រំដែនខ្មែរថៃរហូតដល់ឆ្នាំ ១៩៩៣ ទើបគាត់ត្រឡប់មកវិញ ចំណែកដីឡូតិ៍នេះពីមុនមកមិនទាន់ធ្វើរបងត្រឹមត្រូវទេ ហើយប្រជាជនអាចចេញចូលមកផ្លូវសាធារណៈបានតាមគ្រប់ច្រកទាំងអស់មិនថាដីឡូតិ៍របស់អ្នកណាទេ ។ តែក្រោយមកខ្លួនបានធ្វើរបងដីឡូតិ៍របស់ខ្លួនស្រាប់តែកូនប្រសាររបស់យាយ លាស់ វឿន បាននាំបេអឹមមកគំរាមគំហែងផករបងរបស់ខ្លួនចោល ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោកមេធាវី មៀច សអ៊ាន់ ការពារអោយដើមចោទ និង ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលសវនាការថា : នៅឆ្នាំ ១៩៧៩កូនក្តីរបស់ខ្លួនយាយ លាស់ វឿន បានចូលមករស់នៅលើដីនេះតំណាលគ្នាយាយ យ៉េន គឺយាយ យ៉េន នៅពីមុខយាយ លាស់ វឿននៅពីក្រោយ ហើយយាយ លាស់ វឿន ដើរកាត់តាមដីខាងមុខ ។ ក្រោយមកយាយយ៉េន បានដោះដូរដីនេះអោយទៅលោក អៀង ម៉េងហ៊ាង ពេលនោះសង្កាត់ក៏ដឹងថា យាយ លាស់ វឿន ដើរតាមផ្លូវនេះដែរ ។

១- សូមបដិសេធសាលដីការបស់សាលាឧទ្ធរណ៍

២- សុំរុះរើសំណង់ចេញពីផ្លូវដើរ

៣- សុំសិទ្ធិប្រើប្រាស់ផ្លូវដើរ

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា : បណ្តឹងសាទុក្ខលេខ ៣៩៨ ចុះថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០០០ របស់អ្នកស្រី លាស់ វឿន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៥ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍ ក៏ ដូចតុលាការក្រុងភ្នំពេញដែរ ដែលសំរេចបិទច្រកផ្លូវ ចេញ ចូល ទៅកាន់លំនៅដ្ឋានរបស់ដើមចោទដោយសំអាងទៅលើ

--- ---

លិខិតលេខ ០៨៦_៩៩ ចុះថ្ងៃទី ១៦ ខែ មិនា ឆ្នាំ ១៩៩៩ របស់ការិយាល័យភូមិបាលខណ្ឌមានជ័យ នោះគឺជាការភ័ន្តច្រឡំពីព្រោះថា :

- ក្នុងកំណត់ហេតុយកចម្លើយចុះថ្ងៃទី ១៥ ខែ ឧសភា ឆ្នាំ ១៩៩៨ ចុងចម្លើយបានអះអាងថាពីមុនមកផ្លូវនេះខ្លួនមិនបានបិទទេ ព្រោះផ្ទះខាងក្រោយគ្មានមនុស្ស ។

- តាមរបាយការណ៍ស្តីពីទំនាស់ច្រកផ្លូវចេញ ចូល ក្នុងក្រុមទី ២១ ភូមិទួលរកាចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ១៩៩៨ ចៅសង្កាត់ចាក់អង្រែងក្រោមបានបញ្ជាក់ថាចុងចម្លើយ លោក អៀង ម៉េងហ៊ាង បានសុខចិត្តរកន្លែងទុកច្រកកន្លែងព្រំប្រទល់ដីមានទទឹង ១ម៉ែត្រ សំរាប់អោយភាគី លាស់ រឿន ចេញ ចូល ។

- ក្នុងកំណត់ហេតុផ្សះផ្សាសំរុះសំរួលនៅសាលាសង្កាត់ចាក់អង្រែងក្រោម ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ១៩៩៨ លោក អៀង ម៉េងហ៊ាង ក៏បានយល់ព្រមរកន្លែងទុកផ្លូវ ១ម៉ែត្រ អោយភាគី លាស់ រឿន ធ្វើដំណើរចេញ ចូល ជាបណ្តោះអាសន្ន រង់ចាំការដោះស្រាយលើកទី ២ ទៀត ។

- យល់ឃើញថា : សាលដីការដ្ឋប្បវេណីលេខ ១៥៦ 'ង' ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះមានការខុសឆ្គងទាំងទំរង់ និង គតិច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខគូក្តី

១_ ទទួលបណ្តឹងសាទុក្ខលេខ ៣៩៨ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០០ របស់អ្នកស្រី លាស់ រឿន ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២_ ទុកជាមោឃៈសាលដីការរដ្ឋប្បវេណីលេខ ១៥៦ 'ង' ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣_ បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ៤៥៤ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា _ ឆ្នាំ ២០០០ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤_ រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛ ដែលអ្នកស្រី លាស់ រឿន បានបង់ទុកជាមុនគឺ :

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ឹងចំនួន ៥.០០០៛ ចំនែកប្រាក់នេះត្រូវកាត់ចំនួន ៨០០៛ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ,

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវអោយលោក អៀង ម៉េងហ៊ាង សងប្រាក់ចំនួន ១៩.០០០៛ នេះទៅអោយអ្នកស្រី លាស់ រឿន វិញ ។

៥_ សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ២៩ ខែ_ ឧសភា ឆ្នាំ ២០០១ ។